ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

កញ្ញា ២០០៥ / September 2005

កញ្ញា អ៊ូច ច័ន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុទ្ធា / **Mr. Hing Vutha**

លោក ភីម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយៈ **យូ សិទ្ធីរិទ្ធ**

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទីពីរ ២០០៥ វិនិយោគក្នុងវិស័យកាត់ដេរមាន ២៣,២លានដុល្លារ រឺ ៣៧,៤% នៃវិនិយោគទ្រព្យសកម្មក្នុងផ្នែកឧស្សាហកម្ម រឺ ២៤,២% នៃវិនិយោគទ្រព្យសកម្មដែល CDC អនុម័ត ។ វាធ្លាក់ចុះ ៤៨% ពីត្រីមាសទីមួយ (៤៥លានដុល្លារ) និងកើនជាងពីរដង កាលពីត្រីមាសទីពីរឆ្នាំមុន (១០,១លានដុល្លារ) ។

In the second quarter 2005, a total of $23.2 million was invested in garment sector, representing 37.4 percent of the fixed asset investments in industrial sector or 24.2 percent of total fixed asset investments approved by CDC. It declined by about 48 percent from $45 million in the first quarter. Compared to the second quarter last year, it more than doubled, from $10.1 million.

**Fixed Asset Investments Approved by CDC for Garment Sectors**
(US$ million)




*Note: Data for May-June 2005 exclude expansion project approvals.*
Source: Council for the Development of Cambodia

ជាទូទៅ នៅត្រីមាសទីមួយ-ពីររៀងរាល់ឆ្នាំ ចំនួនភ្ញៀវចូលមកកម្ពុជាហាក់ដូចជាធ្លាក់ចុះ ។ នៅត្រីមាសទីពីរ ២០០៥ ចំនួនភ្ញៀវធ្លាក់ចុះ ២២,៨% មកត្រឹម ២៩៣.៧៦១នាក់ ។ ភ្ញៀវមកតាមយន្តហោះថយចុះ ២៦,៧% មកត្រឹម ១៦៩.៧៨១នាក់ និងភ្ញៀវមកតាមជើងគោក និងទឹកថយចុះ ១៦,១% មកត្រឹម ១២៣.៩៨០ នាក់ ។ ធៀបនឹងត្រីមាសទីពីរមួយឆ្នាំមុន ចំនួនភ្ញៀវមកកម្ពុជា កើនឡើង ៣៥% ។

The number of foreign visitor arrivals to Cambodia generally tends to decline over the first-second quarters in a year. During 2005, arrivals decreased by 22.8 percent, amounting to 293,761 persons in the second quarter. Both arrivals by air and by land and boat declined, by 26.7 percent to 169,781 persons and by 16.7 to 123,980 persons respectively. Compared to the second quarter one year earlier, however, arrivals to Cambodia were about 35 percent higher.

**Foreign Visitor Arrivals to Cambodia by Air, Land and Boat**
(thousand persons)




*Note: Visitor arrivals by land and boat in Q4-04 and Q1 & Q2-05 include visitors to Preah Vihear.*
Source: Ministry of Tourism

នៅត្រីមាសទីពីរ ២០០៥ គំរោងសាងសង់បានអនុម័តនៅភ្នំពេញមានតំលៃ ១០៤,៤លានដុល្លារ ធ្លាក់ចុះបន្តិចពីត្រីមាសមុន ដែលមានតំលៃ ១០៦,១លានដុល្លារ ។ ក្នុងនេះ ការសាងសង់ភូមិគ្រឹះ/ផ្ទះ ថយចុះ ៥៤% មកត្រឹម ៦,៦លានដុល្លារ, ផ្ទះល្វែងកើន ៤២% ដល់ ៦៩,១លានដុល្លារ, ឃ្លាំង/រោងចក្រថយចុះ ៣៣,៦% មកត្រឹម ២៨,៦លានដុល្លារ ។ តំលៃសរុបនៃគំរោងសាងសង់បានអនុម័តកើនយ៉ាងខ្លាំង បើធៀបនឹងត្រីមាសទីពីរឆ្នាំមុន ។

In the second quarter 2005, construction project approvals in Phnom Penh were valued at around $104.4 million, a slight decrease from the preceding quarter when it was $106.1 million. Of this, villa and house construction activities slackened in the second quarter, declining by 54 percent to $6.6 million, while flat construction rose by 42 percent to $69.1 million. Other construction activities, like warehouse or factory construction, also declined, by 33.6 percent to $28.6 million. The total value of construction approvals, however, rose sharply as compared to the second quarter last year.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for June 2005.*
Source: Department of Cadastre and Geography, Municipality of Phnom Penh.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

ថ្លៃទីផ្សារជាមធ្យមនៃប្រេងសាំង និងម៉ាស៊ូត នៅភ្នំពេញ កើនឡើងដល់ ៣.៤៨៩៛/លីត្រ និង ២.៧៩៧៛/លីត្រ នៅខែសីហា ២០០៥ ។ បើធៀបខែនឹងខែ ថ្លៃប្រេងសាំងនៅខែសីហា កើន ៤,៣% លឿនជាងថ្លៃនៅខែកក្កដា ដែលកើន ៣,២% ហើយថ្លៃម៉ាស៊ូតថយចុះមកត្រឹម ៣,៣% ធៀបនឹង ៨,៨% នៅខែកក្កដា ។ ទន្ទឹមនេះ អង្ករនៅភ្នំពេញបន្តឡើងថ្លៃដល់ ១.២៥០៛/គ.ក នៅខែសីហា គឺកើន១០០៛/គ.ក ។

The average market price of gasoline and diesel in Phnom Penh continued to increase, reaching 3,489 riels/litre and 2,797 riels/litre in August 2005. On a month-to-month comparison, gasoline price in August rose by 4.3 percent, faster than in July when it rose 3.2 percent, while diesel price slowed down by 3.3 percent compared to 8.8 percent in July. Meanwhile, the price of rice in Phnom Penh continued to rise, reaching an average price of 1,250 riels/kg in August–100 riels/kg up from July.

**Price of Gasoline, Diesel Oil and Second Quality Rice in Phnom Penh**




Sources: CDRI and National Institute of Statistics

វិទ្យាស្ថានជាតិស្ថិតិ បានចេញផ្សាយនូវទិន្នន័យថ្លៃទំនិញប្រើប្រាស់សរុបនៅភ្នំពេញ ដែលបង្ហាញឱ្យឃើញពីកំនើននៅតែបន្តក្នុងអត្រាប្រចាំឆ្នាំ ៤,១% នៅខែកក្កដា ២០០៥ ។ វាទាក់ទិនជាសំខាន់នឹងថ្លៃម្ហូបអាហារ និងដឹកជញ្ជូន (ថ្លៃប្រេងសាំង) ។ ថ្លៃម្ហូបអាហារកើន ៥,២% និងថ្លៃដឹកជញ្ជូនកើន ១១,៩% ។

The National Institute of Statistics released data on overall consumer prices in Phnom Penh, indicating continued rise at an annual rate of 4.1 percent in July 2005. This seems to be mainly related to food and transportation (fuel) prices. The price of food rose by 5.2 percent and cost of transportation by 11.9 percent.

**Consumer Price Index**

(July–December 2000=100)




*Note: Latest data available are for July 2005*
Source: National Institute of Statistics

អត្រាការប្រាក់សំរាប់កំចីជាប្រាក់រៀល និងដុល្លាររយៈពេល ១២ខែនៃធនាគារធំៗបីគឺ ធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) អេស៊ីលីដា ធនាគារកាណាឌីយ៉ា នៅតែគ្មានការប្រែប្រួលពីខែមិថុនា២០០៤-២០០៥ ។ FTB យកការប្រាក់ ១៨% សំរាប់កំចីជាប្រាក់រៀល និងដុល្លារ ហើយ អេស៊ីលីដា យក ២៤% សំរាប់កំចីដូចគ្នា ។ ប៉ុន្តែធនាគារកាណាឌីយ៉ា យក ២៤% សំរាប់កំចីជាប្រាក់រៀល និង ១៨% សំរាប់កំចីជាប្រាក់ដុល្លារ ។

The interest rate on 12-month riel and dollar loan of the three major banks, Foreign Trade Bank of Cambodia, ACLEDA and Canadia Bank, remained unchanged over June 2004-2005. Foreign Trade Bank charges 18 percent for both riel and dollar loans, while ACLEDA bank charges 24 percent for both riel and dollar loans. However, Canadia bank charges 24 percent for riel loans and 18 percent for dollar loans.

**Interest Rate on 12 -month Loans**

(As of June 2005)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ

# Exchange Rate and Monetary Developments

ក្រោយពីមានការធ្លាក់ចុះអស់ បួនខែជាប់ៗគ្នា ប្រាក់រៀលឡើងថ្លៃបន្តិចវិញ ទល់នឹងដុល្លារUS នៅខែសីហា ២០០៥ ។ អត្រាប្តូរប្រាក់នៅទីផ្សារភ្នំពេញ ជាមធ្យមប្តូរបាន ៤.១៨២៛/ដុល្លារ នៅខែសីហា បើធៀបនឹង ៤.១៨៦,៤៛ /ដុល្លារ នៅខែមុន ។

After depreciating for the fourth consecutive month, the riel gained slightly against the US dollar in August 2005. The market exchange rate in Phnom Penh between the riel and US dollar averaged 4,182 riels/dollar in August, compared to 4,186.4 riels/dollar in the preceding month.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

អត្រាទីផ្សារជាមធ្យមរវាងប្រាក់រៀល និងបាត ប្តូរបាន ១០១,៦៥៛/បាត នៅខែសីហា ២០០៥ ធ្លាក់ថ្លៃ ១,៣% ពីខែមុន ។ នៅពេលដូចគ្នា ប្រាក់រៀលក៏ធ្លាក់ថ្លៃទល់នឹងប្រាក់ដុងវៀតណាមដែរ ដោយប្តូរបាន ២៦,៣៛/ ១០០ដុង ធៀបនឹង ២៦៛/១០០ដុង នៅមួយខែមុន ។

The average market rate between the riel and the Thai baht was 101.65 riels/baht in August 2005, depreciating by 1.3 percent from the preceding month. Meanwhile, the riel also slid against the Vietnamese dong, trading at 26.3 riels per 100 dongs, compared to 26 riels per 100 dongs a month earlier.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI and the *Economist*

នៅខែមិថុនា ២០០៥ រូបិយវត្ថុទូទៅថយចុះ ១% មកត្រឹម ៤.៦២៩,២៥ ពាន់លានរៀល ធៀបនឹងខែឧសភា ។ ក្នុងនេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសថយចុះ ២,៦៨% មកត្រឹម ៨០២,៥លានដុល្លារ (៣.២៩៤,៩៦ ពាន់លានរៀល) ហើយប្រាក់រៀលក្នុងធនាគារកើន ២,២% ដល់ ១៦៦,៩៨ ពាន់លានរៀល ។ ប៉ុន្តែ ប្រាក់រៀលបោះពុម្ពថ្មីកើន ០,៩% ហើយប្រាក់រៀលនៅក្រៅធនាគារ កើនបាន ០,៩% ដល់ ១.១៦៧,៣ពាន់លានរៀល នៅខែឧសភា ។

In June 2005, total liquidity declined by 1 percent to 4,629.25 billion riels, compared to May. Of this, foreign currency deposits decreased by 2.68 percent to about $802.5 million (3,294.96 billion riels), while the riel in bank deposits rose by 2.2 percent to 166.98 billion riels. On the other hand, new riel issues increased by 0.9 percent, and the riel outside banks increased by 0.9 percent to 1,167.3 billion riels in June.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for June 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាសទីពីរ ២០០៥ ការនាំចេញសរុបរបស់កម្ពុជា មានតំលៃ ៥១៥,១ លានដុល្លារ រឺ ៤,១% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន ។ ជាផ្នែកមួយនៃការនាំចេញសរុបរបស់កម្ពុជា ការនាំចេញទៅ US នៅត្រីមាសទីពីរ ២០០៥ មានតំលៃ ៣៣៧,០៨លានដុល្លារ រឺកើន៩,៨% ធៀបនឹងត្រីមាសទីមួយ ។ នៅពេលដូចគ្នា ការនាំចេញទៅប្រទេសអាស៊ាន កើន ៣,២% ដល់ ១១,៤ លានដុល្លារ និងទៅប្រទេសឯទៀតកើន ៤៨,១% ដល់ ៥៩,៨លានដុល្លារ រីឯការនាំចេញទៅអឺរ៉ុប ធ្លាក់ចុះ ២១,៧% មកត្រឹម ១០៦,៨លានដុល្លារ ។

Cambodia's total exports amounted to $515.1 million in the second quarter 2005, 4.1 percent more than in the same quarter last year. As a share of total Cambodia's exports, exports to US in the second quarter 2005 reached $337.08 million, an increase of 9.8 percent compared to the first quarter. At the same time, exports to ASEAN and other countries climbed by 3.2 percent to $11.4 million and by 48.1 percent to $59.8 million respectively, while exports to EU dropped by 21.7 percent to $106.8 million.

**Cambodia's Export by Regions**
(US$ million)




*Note Latest data available are for June 2005.*
Source: Customs and Excise Department

នៅត្រីមាសទីពីរ ២០០៥ ការនាំចូលបារីកើន ៥៨,៧% ដល់ ១០០,៨ ពាន់លានរៀល ធៀបនឹងត្រីមាសទីមួយ ។ នៅពេលដូចគ្នា ការនាំចូលស៊ីម៉ង់ត៍កើន ២០% ដល់ ៥០,៥ពាន់លានរៀល ហើយការនាំចូលដែកធ្លាក់ចុះ ១០% មកត្រឹម ១៨,១ពាន់លានរៀល ។ ស្រដៀងគ្នានេះដែរ បើធៀបនឹងត្រីមាសទីពីរឆ្នាំមុន ការនាំចូលបារី និងស៊ីម៉ង់ត៍កើន ១៨,៧% និង ២៦,៦% ហើយការនាំចូលដែកធ្លាក់ចុះ ៤២,៥% ។

In the second quarter 2005, the value of cigarette imports rose by 58.7 percent to 100.8 billion riels, compared to the first quarter. In the meantime, the value of cement imports increased by 20 percent to 50.5 billion riels, in contrast to steel imports which decreased by 10 percent to 18.1 billion riels. Similarly, compared to the second quarter last year, the imports of cigarette and cement rose by 18.7 percent and 26.6 percent, while imports of steel declined by 42.5 percent.

**Imports of Cigarette and Construction Materials**
(billion riels)




*Note: Latest data available are for June 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

នៅត្រីមាសទីពីរ ២០០៥ ការនាំចូលប្រេងសាំង និងម៉ាស៊ូតមានតំលៃ ១៣៧,៧ ពាន់លានរៀល រឺ ១២,៣%ខ្ពស់ជាងត្រីមាសទីមួយ ។ ការនាំចូលម៉ាស៊ូតកើន ២៣% ដល់ ១០០,៣ ពាន់លានរៀល ហើយការនាំចូលប្រេងសាំងធ្លាក់ចុះ ៩% មកត្រឹម ៣៧,៤ពាន់លានរៀល ។ ពីត្រីមាសទីពីរកាលពីមួយឆ្នាំមុន ការនាំចូលម៉ាស៊ូតថយចុះអស់ ៨,៨% ប៉ុន្តែការនាំចូលប្រេងសាំង កើនបាន ៨,៥% ។

In the second quarter 2005, the value of diesel and gasoline imports amounted to 137.7 billion riels, 12.3 percent more than in the first quarter. Diesel imports increased by 23 percent to 100.3 billion riels, while gasoline imports fell by 9 percent to 37.4 billion riels. From the second quarter one year earlier, diesel imports were 8.8 percent lower but gasoline imports increased by 8.5 percent.

**Imports of Petroleum Products**
(billion riels)




Note: Latest data available are for June 2005. (Excluding public sector imports) Source: Customs and Excise Department

# ប្រភព និង ការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

កម្ពុជាទទួលបានជំនួយសរុប ១.៤៤៨,១២ លានដុល្លារពីទីភ្នាក់ងារពហុភាគី កំឡុងឆ្នាំ១៩៩២-២០០៣ ។ ក្នុងនេះ ភ្នាក់ងារអង្គការសហប្រជាជាតិជាអ្នកផ្តល់ច្រើនជាងគេ ស្មើនឹង ៣២% (៤៦៧,៥៨លានដុល្លារ) ។ ADB ជាអ្នកផ្តល់បន្ទាប់ ស្មើនឹង ៣១% (៤៤៥,០៩លានដុល្លារ) ហើយធនាគារពិភពលោក ស្មើនឹង ២៦% (៣៨១,០២លានដុល្លារ) និងមូលនិធិរូបិយវត្ថុអន្តរជាតិ ស្មើនឹង ១១% (១៥៤,៤៣លានដុល្លារ) ។

Cambodia received a total of $1,448.12 million aid from multi-lateral agencies during the period of 1992-2003. Of this, United Nations Agencies were the largest supplier, making up 32 percent ($467.58 million). The Asian Development Bank was the second, amounting to 31 percent ($445.09 million), while the World Bank and the International Monetary Fund accounted for 26 percent ($381.02 million) and 11 percent ($154.43 million) respectively.

**Multi-Lateral Agencies Development Assistance to Cambodia 1992-2003**

(US$ million)




*Note: Provisional data for 2003*

Source: Council for the Development of Cambodia

សហព័ន្ធអឺរ៉ុបបានផ្តល់ប្រាក់ ១.៣៦៣,០៨ លានដុល្លារសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជាសំរាប់ឆ្នាំ ១៩៩២-២០០៣ ។ គណៈកម្មការអឺរ៉ុប (៣៦៩,៥៧ លានដុល្លារ), បារាំង (៣៦៥,៤៨ លានដុល្លារ), ស៊ុយអែត (១៨០,០៥ លានដុល្លារ), អាឡឺម៉ង់ (១១៩,៩២លានដុល្លារ) និងចក្រភពអង់គ្លេស (១០៥,៩៦លានដុល្លារ) គឺជាអ្នកផ្តល់ច្រើនជាងគេចំនួន ៥ ក្នុងចំណោមប្រទេសសហព័ន្ធអឺរ៉ុប ។

European Union provided $1,363.08 million for development in Cambodia during the period of 1992-2003. European Commission ($369.57 million), France ($365.48 million), Sweden ($180.05 million), Germany ($119.92 million) and United Kingdom ($105.96 million) were the top five suppliers among European Union.

**European Union Development Assistance to Cambodia 1992-2003**

(US$ million)




*Note: Provisional data for 2003*

Source: Council for the Development of Cambodia

នៅឆ្នាំ១៩៩២-២០០៣ ទឹកប្រាក់ចំនួន ១.៩៥១,៤៩លានដុល្លារ ត្រូវបានទទួលជាជំនួយសំរាប់ការអភិវឌ្ឍន៍ពីម្ចាស់ជំនួយទ្វេភាគី ។ ជប៉ុនជាម្ចាស់ជំនួយធំជាងគេដោយបានផ្តល់ ១.១១៩,៩៥លានដុល្លារ បន្ទាប់មកគឺសហរដ្ឋអាមេរិក (៣៥៦,៦៦លានដុល្លារ) ។ ជំនួយ ៤៧៤,៨៨លានដុល្លារទៀត បានមកពីអូស្ត្រាលី ចិន កាណាដា កូរ៉េ រុស្ស៊ី នូវែលហ្សឺឡង់ ស្វីស និងម្ចាស់ជំនួយទ្វេភាគី ។

During 1992-2003, a total of $1,951.49 million was received as development assistance from bi-lateral donors. Japan was the biggest donor, accounting for $1,119.95 million, followed by United States ($356.66 million). The remaining $474.88 million came from Australia, China, Canada, Korea, Russia, New Zealand, Switzerland and other bi-lateral donors during this period.

**Development Assistance to Cambodia by Bi-Lateral Donors 1992-2003**

(US$ million)




*Note: Provisional data for 2003*

Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះបញ្ជីអតិរេកថវិកាចរន្តប្រហែល ៦២ពាន់លានរៀលនៅខែឧសភា ២០០៥ ពី ១២៦,៧ពាន់លានរៀលនៅខែមេសា ។ ប៉ុន្តែអតិរេកចរន្ត កើន ៣,៦ពាន់លានរៀល ពីខែឧសភា ២០០៤ ។

The Ministry of Economy and Finance registered a current budget surplus of about 62 billion riels in May 2005, from 126.7 billion riels in April. However, the current surplus was 3.6 billion riels up from May 2004.

**Current Budget Operations**
(billion riels)




*Note: Provisional for Jan-Dec 2004 and Jan-May 2005.*
Source: Ministry of Economy and Finance

នៅខែឧសភា ២០០៥ ចំនួលថវិកាចរន្ត មាន ១៧៤,៨ ពាន់លានរៀល រឺ ១៥,៨% តិចជាងខែមេសា ។ ការថយចុះនេះ បណ្តាលមកពីការថយចំនួលពន្ធក្នុងស្រុក (ថយ ២១,៨%), ចំនួលពន្ធពីការនាំចូល និងនាំចេញ (ថយ ៣,៣%) និងចំនួលមិនមែនពន្ធ (ថយ ៣៩,៣%) ។ ធៀបនឹងខែឧសភា ២០០៤ ចំនួលចរន្តកើន ២០,៨% ។

In May 2005, current budget revenue was 174.8 billion riels, 15.8 percent lower than in April. The decrease was attributable to a decline in revenues from domestic taxes (by 21.8 percent), tax revenues derived from import and export (by 3.3 percent), and non-tax revenue (by 39.3 percent). Compared to May 2004, current revenues were 20.8 percent higher during this period.

**Current Budget Revenue**
(billion riels)




*Note: Provisional for Jan-Dec 2004 and Jan-May 2005.*
Source: Ministry of Economy and Finance

នៅខែឧសភា ២០០៥ ចំនាយថវិកាចរន្តកើន ៣៩,៤% ដល់ ១១២,៨ពាន់លានរៀល បើធៀបនឹងខែមេសា ។ រឿងនេះបណ្តាលជាសំខាន់មកពីកំនើនយ៉ាងខ្លាំងនៃចំនាយលើការការពារជាតិ និងសន្តិសុខពី ២,១ពាន់លានរៀលនៅខែមេសា ដល់ ៣២,៩ពាន់លានរៀលនៅខែឧសភា ។ កំឡុងពេលនេះ ចំនាយខាងសង្គមកិច្ច ក៏កើនឡើងដែរ (កើន ៩,៦% ដល់ ៣៤,៥ពាន់លានរៀល) ប៉ុន្តែចំនាយខាងរដ្ឋបាលទូទៅ និងសេដ្ឋកិច្ច ធ្លាក់ចុះតិចតួចគឺ ៦,៦% មកត្រឹម ២៥,៨ពាន់លានរៀលនិង ១,៦% ត្រឹម ៨,៩ពាន់លានរៀល ។

In May 2005, current budget expenditure increased by 39.4 percent to 112.8 billion riels, compared to April. This was mainly due to a sharp increase in expenditure on defence and security, from 2.1 billion riels in April to 32.9 billion riels in May. During this period, social spending also increased, by 9.6 percent to 34.5 billion riels, but general and economic administration spending dropped marginally, by 6.6 percent to 25.8 billion riels and by 1.6 percent to 8.9 billion riels respectively.

**Current Budget Expenditure**
(billion riels)




*Note: Provisional for Jan-Dec 2004 and Jan-May 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមិថុនា ២០០៥ ការនាំចេញទំនិញរបស់ US សឹងគ្មានការប្រែប្រួល ហើយការនាំចេញរបស់ជប៉ុន និងសហគមន៍អឺរ៉ុបបែរជាកើនឡើង ។ ការនាំចេញរបស់ជប៉ុនកើនបាន ១៧% ពីខែមុន និង ៦.៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនដល់ ៥០១.៧៧ពាន់លានដុល្លារ ។ ការនាំចេញនៃប្រទេសសហគមន៍អឺរ៉ុប កើន ៩% ធៀបនឹងខែមុន និង ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

In June 2005, the exports of goods from the US were virtually unchanged, while exports from Japan and EU area increased. The US exports of goods in June were US$ 74.46 billion compared to US$ 74.50 billion in May. Japan's exports in June increased by 17 percent from last month and 6.6 percent from the same month last year reaching US$ 50.77 billion. Japan's major export products are transport and electric equipment, machinery, chemicals and metals. The exports from the Euro zone in June increased by 7 percent compared to the same month last year and 9 percent compared to the preceding month, reaching US$ 84.47 billion.

**Exports of Goods from the US, EU area and Japan** (Billion of US$)




Source: BEA, Eurostat and JETRO

នៅខែមិថុនា ២០០៥ ការនាំចេញរបស់កូរ៉េខាងត្បូង កើនឡើង ហើយការនាំចេញរបស់តៃវ៉ាន់ធ្លាក់ចុះ ។ ការនាំចេញរបស់កូរ៉េកើន ២% ពីខែឧសភាដល់ ២៣.៧៣ពាន់លានដុល្លារ ។ នៅខែមិថុនា ការនាំចេញរបស់តៃវ៉ាន់ធ្លាក់ចុះ ៩% ពីខែមុន មកត្រឹម ១៤.៨៨ពាន់លានរៀល ។

In June 2005, the exports from South Korea rose, while exports from Taiwan fell. Korea's exports in June increased by 2 percent compared to May, reaching US$ 23.73 billion. Machinery & transport equipment, which represents 61 percent of total exports, rose 3 percent, while chemical products and miscellaneous manufactured articles rose 9 percent and 7 percent respectively from the previous month. Taiwan's exports of goods in June decreased by 9 percent from the previous month to US$ 14.88 billion. The decline reflects the decrease in exports of industrial products such as machineries and electrical equipment and basic metals and articles.

**Exports of Goods: South Korea and Taiwan** (Billion of US$)




Source: National Statistics Department of Korea and Taiwan

នៅត្រីមាសទីពីរ ២០០៥ ការនាំចេញទំនិញរបស់សិង្ហបុរី ថៃ និងម៉ាឡេស៊ីកើនយឺតជាងមុន ។ ការនាំចេញរបស់សិង្ហបុរីគឺ ៨២.៧២ពាន់លានដុល្លារ ថៃ ២៦.៦៣ពាន់លានដុល្លារ និងម៉ាឡេស៊ី ៣៤.៤០ពាន់លានដុល្លារ ។

In the second quarter 2005, exports of goods in Singapore, Thailand and Malaysia increased more slowly. Singapore's exports of goods in second quarter 2005 were US$ 82.72 billion, a 9 percent increase from the previous quarter and 10.5 percent increase from the same quarter 2004. The exports of goods from Thailand rose to US$26.63 billion from US$25.2 billion in the first quarter 2005.Thailand's major export products are manufacturing goods, high-tech products, resource base products and agriculture products. Malaysia’s exports of goods in the second quarter 2005 rose by 7 percent from the previous quarter reaching US$ 34.40 billion.

**Exports of Goods: Some ASEAN Countries** (Billion of US$)




Source: Country's national statistic office and national banks

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation rates in Selected Economic Partners of Cambodia

ការធ្លាក់ចុះថ្លៃគ្រឿងម្ហូបអាហារ និងថាមពល ធ្វើឱ្យជនជាតិអាមេរិកមានអារម្មណ៍ធូរស្រាលជាងមុន ក្រោយពីរងការលំបាកមក ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅ US កើនបាន ២,៥% ក្នុងឆ្នាំរហូតដល់ខែមិថុនា ជាភស្តុតាងថាអតិផរណា មិនបានគំរាមកំហែងភ្លាមៗដល់សេដ្ឋកិច្ច US ទេ ។ ពេលដូចគ្នា អត្រាប្រែប្រួលប្រចាំឆ្នាំនៃអតិផរណាទំនិញប្រើប្រាស់កើន ២,១% នៅអឺរ៉ុប ដោយសារថ្លៃថាមពលកើនឡើង និងមានអត្រាធ្លាក់ចុះ ០,៥% នៅជប៉ុន ដោយសារថ្លៃម្ហូបអាហារស្រស់ៗធ្លាក់ចុះ ។

The decline in grocery and energy prices gave Americans a bit of relief after being hard hit by soaring food and energy costs. The U.S consumer price index increased moderately to 2.5 percent in the year to June, providing fresh evidence that inflation is not an immediate threat to the U.S economy. During the same period, the annual rate of change of consumer inflation rose to 2.1 percent in EU due to higher energy costs but declined by 0.5 percent in Japan due to drop in prices of fresh food.

### Inflation Rate in the US, Europe and Japan

(percentage change over the previous year)




*Note: The latest data available are for June 2005.*
Sources: IMF and the *Economist* (Aug. 13-19, 2005)

នៅខែមិថុនា ២០០៥ ថ្លៃទំនិញប្រើប្រាស់សរុបនៅហុងកុង កើន ១,២% ធៀបនឹងឆ្នាំមុន រី ០,៨% ខ្ពស់ជាងកំនើនឆ្នាំលើឆ្នាំនៅខែឧសភា ។ រឿងនេះបណ្តាលមកពីការកាត់បន្ថយថ្លៃជួលផ្ទះ និងចំនាយទូរស័ព្ទ និងសេវាទូរគមនាគមន៍ផ្សេងទៀត ។ នៅពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង មានអត្រាប្រចាំឆ្នាំធ្លាក់ ១,៦% និង ២,៧% ក្នុងឆ្នាំរហូតដល់ខែមិថុនា ។

Hong Kong overall consumer prices rose by 1.2% in June 2005 over a year earlier, larger than the 0.8% year-on-year increase in May. This was mainly attributable to the reduction in private housing rentals and the charges of telephone and other communications services. During the same period, the annualised consumer inflation in China and South Korea respectively decelerated to 1.6 percent and 2.7 percent in the year to June.

### Inflation Rate in China, Hong Kong and South Korea

(percentage change over the previous year)




*Note: The latest data available are for June 2005.*
Sources: IMF and the *Economist* (Aug. 13-19, 2005)

ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរីធ្លាក់ចុះ ០,២% នៅខែមិថុនា ធៀបនឹងឆ្នាំមុន ដែលបង្ហាញពីការធ្លាក់ថ្លៃលំនៅដ្ឋាន ដឹកជញ្ជូន និងទូរគមនាគមន៍ព្រមទាំងសំលៀកបំពាក់ និងស្បែកជើង ។ ខណៈនោះ ម៉ាឡេស៊ីមានអតិផរណាកើនជាងពីរដងធៀបនឹងឆ្នាំមុន ដល់ ៣,២% នៅខែមិថុនា ។ រីឯថ្លៃទំនិញប្រើប្រាស់សរុបនៅថៃកើន ៣,៨%ក្នុងឆ្នាំរហូតដល់ខែមិថុនា ។

Singapores consumer prices fell by 0.2 percent in June from a year earlier largely reflected in lower costs of housing and transport & communication as well as cheaper clothing and footwear. Meanwhile Malaysia’s inflation rate has more than doubled in the past year, rising to 3.2 percent in June, as the Malaysian Government raised fuel prices to cut its fuel subsidy costs and increased taxes on tobacco and alcohol to further trim the budget deficit. At the same time, overall prices in Thailand rose to 3.8 percent in the year through June.

### Inflation Rate in Selected ASEAN Countries

(percentage change over the previous year)




*Note: The latest data available are for June 2005.*
Sources: IMF and the *Economist* (Aug. 13-19, 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rate in the World Markets

នៅខែសីហា ២00៥ ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុនានា ។ វាប្តូរបាន 0,៨១អឺរ៉ូ ចុះថ្លៃពី 0,៨៣ នៅខែមុន និងប្តូរបាន ១១0,៥៩យ៉េន ចុះថ្លៃពី ១១១,៨៦ ។ ប្រាក់អឺរ៉ូឡើងថ្លៃដោយមានសញ្ញាបង្ហាញថា សេដ្ឋកិច្ចក្នុងតំបន់នោះមានភាពទាក់ទាញ វីឯប្រាក់យ៉េនឡើងថ្លៃដោយសារអតិរេកគណនីចរន្តរបស់ជប៉ុន និងវិនិយោគបរទេសលើហ៊ុនក្នុងស្រុក កើនឡើងព្រមទាំងមានកំនើនសេដ្ឋកិច្ចខ្ពស់ជាងមុន ។

In August 2005, the US dollar weakened against most major currencies. It was traded at 0.81 against the euro, down from 0.83 a month earlier, and at 110.59 against the yen, down from 111.86. The euro gain was mainly due to signs that the region’s economy was gaining traction, while the yen appreciation can be attributed to the surplus in Japan's current account, and more foreign investment in local equities as well as accelerating economic growth.

## Euro and Japanese Yen Against the US Dollar




*Note: Data are up to 26 Aug. 2005*
Sources: The Federal Reserve Bank of New York

នៅខែសីហា ២00៥ ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃ ដោយសារការបញ្ជាទិញទំនិញពី US ធ្លាក់ចុះនៅខែកក្កដា ធ្វើអោយប្រាក់ដុល្លារធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ប្រាក់វ៉ុនក៏ទទួលបានការគាំទ្រពីការរំពឹងជាថ្មីថា ក្រុងប៉េកាំងនឹងធ្វើឱ្យប្រាក់យ៉ុនឡើងថ្លៃ មុនពេលលោកប្រធានាធិបតី ទៅធ្វើទស្សនកិច្ចជាលើកដំបូងនៅUS ។ ក្នុងពេលដូចគ្នា ដុល្លារហុងកុងប្តូរបាន ៧,៧៧ ទល់នឹងដុល្លារអាមេរិក ។

In August 2005, the South Korean won edged higher as weak orders for U.S durable goods in July hurt the greenback against most major currencies. The South Korean won also received some support from renewed expectations that Beijing may let the yuan appreciate in the run up to President Hu Jintao's first visit to the US since he became president in 2003. During the same period the Hong Kong dollar was traded at 7.77 against its US counterpart showing no change from the previous month.

## South Korean Won and Hong Kong Dollar Against the US Dollar




*Note: Data are up to 26 Aug. 2005*
Sources: The Federal Reserve Bank of New York

នៅខែសីហា ២00៥ ដុល្លារសិង្ហបុរី ឡើងថ្លៃទល់នឹងដុល្លារUS ដោយឡើងដល់ ១,៦៥៨ ពី ១,៦៨១ នៅខែមិថុនា ។ នៅពេលដូចគ្នា ប្រាក់បាតថៃក៏ឡើងថ្លៃទល់នឹងដុល្លារUSដែរ ដោយប្តូរបាន ៤១,១១បាត/ដុល្លារ ថ្លៃជាងខែមុន ១,៤% ។ ការឡើងថ្លៃរូបិយវត្ថុទាំងពីរនេះ បង្ហាញពីការប្រមើលមើលថា ចិននឹងអនុញ្ញាតឱ្យរូបិយវត្ថុខ្លួន ឡើងថ្លៃថែមទៀត ហើយការបញ្ជាទិញទំនិញពីរោងចក្រអាមេរិកទំនងជាធ្លាក់ចុះ ។

In August 2005, the Singapore dollar gained in strength against the US greenback, appreciating to 1.658 from 1.681 in June 2005. At the same time, the Thai baht also strengthened against the US dollar, trading at 41.11 baht/USD, a 1.4 percent appreciation from a month earlier. The gains recorded by the Singapore dollar and the Thai bath also reflect the speculation about the Chinese move to allow its currency to further appreciate, and the likely decline in orders at US factories for durable goods.

## Thai Baht and Singaporean Dollar Against the US Dollar




*Note: Data are up to 26 Aug. 2005*
Sources: The Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែមិថុនា ថ្លៃអង្ករពិភពលោកបន្តមាននិន្នាការធ្លាក់ចុះ ។ ថ្លៃនៅអន្តរជាតិធ្លាក់ចុះអស់ ៣,២ពិន្ទុ ធៀបនឹងខែមុនពី ១១៦,៣ពិន្ទុ នៅខែមិថុនា មកត្រឹម ១១៣,១ពិន្ទុនៅខែកក្កដា ។ ថ្លៃអង្ករនៅទីផ្សារ US ធ្លាក់ចុះពី ៣០៩ដុល្លារ/តោន មកត្រឹម ២៩៦ដុល្លារ/តោន ដោយសារការនាំចេញនៅឆ្នាំនេះមានអតិរេក ។ នៅថៃ អង្ករធ្លាក់ថ្លៃដោយសារថយចុះតំរូវការនាំចេញ ។ អង្ករថៃ 100%B ថ្លៃ ២៨០ដុល្លារ/តោន ធៀបនឹង ២៨៦ដុល្លារ/តោននៅខែមិថុនា ។

In July, the world rice price continued its downward trend. International prices (IPO) went down by 3.2 points from the previous month from 116.3 points in June to 113.1 points in July. The rice price in US markets decreased from US$309 per ton in June to US$296 per ton due to an increased exportable surplus for this year. In Thailand, prices declined in the face of falling demand for exports. The Thai100%B was at US$ 280 per ton against US$ 286 per ton in June.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Source: Osiriz/InfoArroz and InterRice.

នៅខែសីហា ថ្លៃសណ្តែកសៀង និងពោតធ្លាក់ចុះ ។ សណ្តែកសៀង លក់ក្នុងតំលៃ ២១៨,២ដុល្លារ/តោននៅខែសីហា ធៀបនឹង ២៦៣,៩ដុល្លារ/តោននៅខែកក្កដា ។ តំលៃនេះថយចុះ ៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ពោតនៅខែសីហាចុះថ្លៃ ៥% ធៀបនឹងខែមុន លក់បាន ៩៨,៦២ដុល្លារ/តោន ធៀបនឹង ១០៤,២៥ដុល្លារ/តោននៅខែកក្កដា ។ ប្រេងឆាធ្លាក់ថ្លៃតិចតួចមកត្រឹម ៤១៧ដុល្លារ/តោននៅខែកក្កដា ពី ៤១៩ដុល្លារនៅខែមិថុនា ។

In August, the price of soybean and maize went down. Soybean was sold at US$218.2 per ton in August against US$263.9 per ton in July. The amount is about 7 percent lower than the price in the same month last year. The price of maize in August declined by 5 percent compared to the previous month selling at US$98.62 per ton in August and US$ 104.25 per ton in July. The price of palm oil fell slightly to US$ 417 per ton in July from US$ 419 in June.

**International Prices of Palm Oil and Groundnuts** (US$/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែសីហា ប្រេងឆៅ និងសាំងបន្តឡើងថ្លៃ ។ ថ្លៃលក់ដល់ដៃនៃប្រេងឆៅរបស់បណ្តាប្រទេស OPEC នៅខែសីហាគឺ ៥៧,៧៣ដុល្លារ/ធុង រឺ ៧% ខ្ពស់ជាងនៅខែមុន និង ៤៨% ខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ។ ថ្លៃសាំងធម្មតានៅឈូងសមុទ្រអាមេរិកនា ខែសីហា កើន ៧% ពីខែមុនដោយលក់ក្នុងតំលៃ ៤៥,២៥សេន/លីត្រ ធៀបនឹង ៤១,២១សេន/លីត្រនៅខែកក្កដា ។

In August, the price of crude oil and gasoline continued to rise. The OPEC spot price of crude oil in August was US$ 57.73 per barrel, 7 percent higher than the previous month and a 48 percent increase from the same month last year. The conventional regular gasoline in US Gulf Coast in August rose by 7 percent from the previous month selling at 45.25 cents per litre against 41.21 cents per litre in July.

**Prices of Crude Oil and Gasoline**




***Note: Data are up to 23 August*** *2005*
*Sources: Energy Information Administration*

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

| | |
|---|---|
| **តំបន់សេដ្ឋកិច្ចពិសេស សម្ភោធនៅព្រំដែនកម្ពុជា-វៀតណាមៈ** តំបន់សេដ្ឋកិច្ចពិសេសមួយបានសម្ភោធ នៅបាវិត ខេត្តស្វាយរៀង ជិតព្រំដែនកម្ពុជា-វៀតណាម ក្នុងគោលដៅទាក់ទាញវិនិយោគបន្ថែមទៀត ។ តំបន់សេដ្ឋកិច្ចពិសេស ម៉ាន់ហាតាន (ស្វាយរៀង) ត្រូវបានបង្កើតដោយក្រុមអន្តរជាតិតៃវ៉ាន់ **ម៉ាន់ហាតាន** ហើយវាលើកទឹកចិត្តដល់រោងចក្រនានាលើៈ ការលើកលែងចំណូលពន្ធចំនួន៥ឆ្នាំ គ្មានពន្ធនាំចូលលើបរិក្ខារ គ្រឿងបន្លាស់ និងសំភារៈសាងសង់ ។ លើសពីនេះ តំបន់សេដ្ឋកិច្ចក៏មានលក្ខណៈអំណោយផលពិសេសៗ រួមមាន គ្មានពន្ធអាករបន្ថែមលើប្រតិបត្តិការ, សិទ្ធប្រើប្រាស់ដី ៥០ឆ្នាំ និងច្រកទ្វារតែមួយសំរាប់ប្រតិបត្តការពាណិជ្ជកម្ម ទាំងការនាំចេញ និងការនាំចូល ។ ផែនការដំបូងសំរាប់តំបន់នេះ គឺត្រូវអភិវឌ្ឍន៍ផ្ទៃដី ២៤០ហិកតាក្នុង៣ដំណាក់កាល ។ នៅពេលដំណាក់កាលទីមួយបានបញ្ចប់ នឹងមានប្រហែល៣០វិនិយោគិន ដោយមានដីរោងចក្រ ៤០០.០០០ម$^{២}$ នឹងផ្តល់ការងារប្រហែល ១៥.០០០ ហើយតំលៃនាំចេញប្រចាំឆ្នាំសរុបប្រហែល ៣០០លានដុល្លារ ។ *(ស្រង់ពីកាសែតស៊ិនហួរ)* | ***Special economic zone inaugurated on Cambodia, Vietnam border:*** A Special Economic Zone was inaugurated on Thursday at Bavet, Svay Rieng province near the Cambodian and Vietnamese border, aimed at attracting more investment in the country. The Manhattan (Svay Rieng) Special Economic Zone was developed by the Manhattan International Group of Taiwan and it offers some incentives for firms: exemption of company income tax for five years, and no import taxes for equipment, parts and construction materials. Moreover, the zone also enjoys special preferential conditions including no VAT on transactions, 50 year land-lease rights, and a single window for trade operations, both exports and imports. Initial plan for the zone is to develop 240 hectares in three-phases. When Phase 1 is completed, there will be around 30 investors with total factory space of 400, 000 square meters. Total employment could reach 15,000 workers and total annual export values near 300 million US dollars. *(Cited from Xinhua 11 August, 2005)* |
| **កម្ពុជានឹងបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយទៀតៈ** ក្រុមហ៊ុនវិនិយោគ អេតវូត បានប្រកាសផែនការរបស់ខ្លួនថានឹងបង្កើតតំបន់សេដ្ឋកិច្ចនៅក្រុងព្រះសីហនុ ដែលនឹងស្វែងរកវិនិយោគបែបរោងចក្រគ្រប់ប្រភេទ រួមមាន រោងចក្រកាត់ដេរ រោងចក្រអគ្គីសនី និងរោងចក្រនានា ដើម្បីផលិតផលិតផលសំរាប់ប្រើប្រាស់ប្រចាំថ្ងៃ ។ ក្រុមហ៊ុនទទួលបានការអនុមតិឱ្យកសាងផ្លូវមួយទៅកាន់តំបន់នោះ មានតំលៃ ៦,៩លានដុល្លារ ។ នេះជាតំបន់សេដ្ឋកិច្ចទីពីរនៅក្នុងកម្ពុជា ។ តំបន់ទីមួយនៅខេត្តស្វាយរៀងព្រំដែនកម្ពុជា-វៀតណាមបានចាប់ផ្តើមកាលពីសប្តាហ៍មុន ។ កម្ពុជាក៏គ្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកោះកុង តាកែវ កំពង់ចាម ក្រចេះ និងខេត្តបន្ទាយមានជ័យផងដែរ ។ | ***Cambodia to build another special economic zone:*** Cambodia's Attwood Investment Group has unveiled its plan to build a special economic zone in Sihanoukville province, which will seek every type of factory, including garment and textile factories, power plants and factories to produce products for daily use. The group has received approval to build a 6.9 million USD road to the new zone. This is the second economic zone to be built in Cambodia. Construction of the first one, in Svay Rieng province on the Cambodia-Viet Nam border started last week. Cambodia also plans to build special economic zones in Koh Kong, Takeo, Kompong Cham, Kratie, and Banteay Meanchey provinces. *(Cited from VNA, 31 August, 2005)* |
| **សហរដ្ឋអាមេរិក-ចិន ផ្តើមជជែកពីវាយនភណ្ឌសំខាន់ៗៈ** មន្ត្រីពាណិជ្ជកម្ម US ផ្តើមពិភាក្សាការងារសំខាន់ៗជាមួយដៃគូនៅក្រុងប៉េកាំងក្នុងគោលដៅគ្រប់គ្រងកំរិតនៃការនាំចេញសំលៀកបំពាក់របស់ចិន ។ ការចរចានេះជាកិច្ចប្រឹងប្រែងរបស់ប្រទេសទាំងពីរ ដើម្បីឈានដល់ការព្រមព្រៀងលើរបៀបគ្រប់គ្រងការលក់របស់ចិនទៅ US ។ ការនាំចូលបានកើនឡើងតាំងពីដើមឆ្នាំពេលដែលកូតាវាយណភណ្ឌលើពិភពលោកត្រូវបានលុបចោល ។ | ***US-China begin key textile talks: U***S trade officials have begun vital talks with their counterparts in Beijing in an effort to cap the growing level of China's clothing exports. The negotiations are the latest attempt by the two countries to reach an agreement on how to control Chinese sales to the US. Imports have surged since the start of the year when quotas governing worldwide textile sales were abolished. |
| **គ្មានសេចក្តីសំរេចអ្វីទេក្នុងការជជែករវាងចិន និងសហគមន៍អឺរ៉ុបៈ** មន្ត្រីសហគមន៍អឺរ៉ុប និងចិន បានសន្និដ្ឋានលើការពិភាក្សាខាងពាណិជ្ជកម្ម ហើយហាក់ដូចជាបានឈានដល់កិច្ចព្រមព្រៀង ដែលនឹងអាចដោះស្រាយដល់វិបត្តិថ្មីៗនេះ ។ ប៉ុន្តែ កិច្ចព្រមព្រៀងត្រូវមានការអនុម័តពីសភាសហគមន៍អឺរ៉ុប មុននឹងដាក់ឱ្យអនុវត្ត ។ | ***No breakthrough in China-EU talks:*** EU and Chinese officials have concluded their trade talks and appear to have reached an agreement that would resolve the current crisis. The deal however will need approval of the EU parliament before it can be given effect. |